# ព្រះរាជក្រម

នស/រកម/០៦១០/០១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យទៅក្រុមហ៊ុនខេមបូឌាន ទ្រែនមីស៊ិន លីមីធីត ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា ឲ្យទៅក្រុមហ៊ុន
# ខេមបូឌាន ថ្រែនមីសិន លីមីធីត

**មាត្រា ១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុនខេមបូឌាន ថ្រែនមីសិន លីមីធីត ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង ក្រុមហ៊ុនខេមបូឌាន ថ្រែនមីសិន លីមីធីត និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី រវាងអគ្គិសនីកម្ពុជា និង ក្រុមហ៊ុនខេមបូឌាន ថ្រែនមីសិន លីមីធីត ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ កាលថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ។ ការធានានេះមានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១០ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកម.០៦១០.៥៤៣

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខៈ ៤៧៧ ច.ល

ហត្ថលេខា

គាត ឈន់

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនគេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០០១......សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១០

# លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

ជូនចំពោះ : **លោក** H'NG CHUN HSIANG
**ក្រុមហ៊ុន ខេមបូឌាន ត្រែនមីសិន លីមីធីត**

អាស័យដ្ឋាន: រោងចក្រអគ្គិសនីទី២, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែលើ, ខណ្ឌមានជ័យ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ទូរសារ : 855 23 425 990

**យោង** :

(ក) សិទ្ធិប្រទាន លេខ ០៧ សប្រទ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (លិខិតសិទ្ធិប្រទាន ក្នុងឧបសម្ព័ន្ធ១) ។

(ខ) **កិច្ចព្រមព្រៀងអនុវត្តគម្រោង** (IA) ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ដែលបានចុះហត្ថលេខា រវាង រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល «ក្រ.ឧ.រ.ថ»** និង **ក្រុមហ៊ុន ខេមបូឌាន ត្រែនមីសិន លីមីធីត** (Cambodian Transmission Limited) **«ក្រុមហ៊ុន»** ។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យ លេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅ ផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នក បន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ **«អ.ក»** ដែលបានចុះកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី (PTA) ជាមួយ **ក្រុមហ៊ុន** ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១០ ។

(ឃ) **រាជរដ្ឋាភិបាលកម្ពុជា** បានយល់ព្រមផ្តល់ : (១)-ការធានាលើការទូទាត់ថ្លៃកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី សម្រាប់ការប្រើប្រាស់គម្រោង ១០០% (មួយរយភាគរយ) ក្នុងករណីដែល **អ.គ** មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់ថ្លៃទិញមធ្យោបាយគម្រោង ដោយបញ្ចប់កិច្ចព្រមព្រៀង ស្របតាមកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និង/ឬកិច្ចព្រមព្រៀងអនុវត្តគម្រោង ក្នុងករណីដែល **ក្រុមហ៊ុន** មិនអាចដំណើរការអាជីវកម្មបាន ដោយហេតុកើតចេញពីព្រឹត្តិការណ៍ប្រធានសក្តិផ្នែកនយោបាយ ។

(ង) តាមការតម្រូវក្នុងផ្នែក ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង **រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «ក្រ.ស.ហ.វ»** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា **«អ្នកធានា»** បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដោយ **អ.គ/ក្រ.ឌ.ក.៩** ស្របតាមកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និងកិច្ចព្រមព្រៀងអនុវត្តគម្រោង ។

**ដូច្នេះ យើងខ្ញុំសូមធានា ថា:**

១. **អ្នកធានា** ធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យ **ក្រុមហ៊ុន** នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ **អ.គ/ក្រ.ឌ.ក.៩** ឱ្យ **ក្រុមហ៊ុន** ស្របតាមកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ដែល **អ.គ/ក្រ.ឌ.ក.៩** ខកខានពុំបានទូទាត់អនុលោមតាមអាណត្តិ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យ **ក្រុមហ៊ុន** គ្រប់ពេលដោយ **ក្រ.ឌ.ក.៩** ឬ **អ.គ** ស្របតាមកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬអសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង **ក្រ.ឌ.ក.៩** ឬ **អ.គ** ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងតម្រូវការទូទាត់ពី **អ្នកធានា** **ក្រុមហ៊ុន** ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី **ក្រ.ឌ.ក.៩** ឬ **អ.គ** ។ ក្រោយរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយប័ត្រ ដូចមានចែងក្នុងផ្នែក ១១.១ នៃកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ឬសំណើសុំទូទាត់ណាមួយពី **ក្រុមហ៊ុន** ទៅ **ក្រ.ឌ.ក.៩** ឬ **អ.គ** ហើយត្រូវបានទទួលដោយ **ក្រ.ឌ.ក.៩** ឬ **អ.គ** **ក្រុមហ៊ុន** អាចជូនដំណឹងទៅ **អ្នកធានា** ជាលាយលក្ខណ៍អក្សរ ថាការទូទាត់ដោយ **ក្រ.ឌ.ក.៩** ឬ **អ.គ** បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពី **អ្នកធានា** ស្របតាមលិខិតធានានេះ ហើយ **អ្នកធានា** ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ។ ការយឺតយ៉ាវក្នុងការទូទាត់របស់ **អ្នកធានា** ក្រោមកិច្ចព្រមព្រៀងនេះ ត្រូវគិតការប្រាក់តាមអត្រាការប្រាក់ប្រចាំឆ្នាំ LIBOR បូកបី ៣% (បីភាគរយ) ។ ហើយពុំមានសំណើណាមួយ

ដែលធ្វើឡើងដោយ **ក្រុមហ៊ុន** ស្របតាមកិច្ចព្រមព្រៀងនេះ ដែលប៉ះពាល់ ឬជំទាស់សិទ្ធិរបស់ **ក្រុមហ៊ុន** ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយប័ត្រ មិនបានទូទាត់ផ្សេងទៀត ។

ទឹកប្រាក់ទាំងអស់ ដែល **អ្នកធានា** ត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែល **ក្រុមហ៊ុន** បានកំណត់ ជាដុល្លារអាមេរិកឱ្យ **ក្រុមហ៊ុន** ។

៤. រាល់ការធ្វើសំណើសុំទូទាត់ណាមួយ ដោយអនុលោមតាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬតាមរយៈបុគ្គល ដែលជាមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់ របស់ **ក្រុមហ៊ុន** នៅការិយាល័យរបស់ **អ្នកធានា** និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់ របស់ **ក្រុមហ៊ុន** ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា :

"យើងខ្ញុំ សូមបញ្ជាក់ថា :

(១) **ក្រុមហ៊ុន ខេមបូឌាន ខ្វែនម៍សិន លីមីធីត «ក្រុមហ៊ុន»** បានធ្វើសំណើទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **«អ្នកធានា»** ក្នុងចំនួនទឹកប្រាក់..................... (បញ្ចូលទឹកប្រាក់) ជាដុល្លារអាមេរិក ស្របតាមផ្នែក១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី ........ ខែ ......... ឆ្នាំ ......... រវាង **អ្នកធានា** និង **ក្រុមហ៊ុន** ។

(២) ចំនួនទឹកប្រាក់កំណត់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ (**ក្រ.ខ្ញ.ក.ម ឬ អ.គ**) ស្របតាមកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ឬកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាង **ក្រុមហ៊ុន** និង **ក្រ.ខ្ញ.ក.ម** ឬ **អ.គ** និងពុំមានផ្នែកណាមួយនៃចំនួនទឹកប្រាក់ ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃជម្លោះ រវាង **ក្រ.ខ្ញ.ក.ម/អ.គ** និង **ក្រុមហ៊ុន** ។

(៣) សំណើសុំទូទាត់ពី **ក្រ.ខ្ញ.ក.ម/អ.គ** ជាលាយលក្ខណ៍អក្សរ បានធ្វើរួចហើយ ។

(៤) ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ **ក្រ.ខ្ញ.ក.ម/អ.គ** រហូតដល់ថ្ងៃនេះ ។"

៥. **អ្នកធានា** សូមអះអាង និងធានា នៅថ្ងៃនេះថា :

**អ្នកធានា** មានសិទ្ធិពេញលេញ និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេត តាមអាណត្តិ និងបញ្ញត្តិ នៃលិខិតធានានេះ ។

លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ ដែល **អ្នកធានា** ត្រូវអនុវត្ត អនុលោមតាមអាណត្តិរបស់លិខិតធានានេះ ។

រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រមដែលតម្រូវឱ្យមាន ត្រូវបានទទួលក្រោមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិលិខិតធានានេះ ។

កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានា របស់ **អ្នកធានា** ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់ **អ្នកធានា** ដើម្បីអនុវត្តកាតព្វកិច្ចទាំងនេះ សម្រាប់ផ្តល់ការជឿទុកចិត្ត និងកិត្តិយសរបស់ **អ្នកធានា** ។

**អ្នកធានា** បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយ **អ្នកធានា** តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ ។

ប្រសិនបើមានបណ្តឹងណាមួយចំពោះ **អ្នកធានា** ឬចំពោះទ្រព្យសម្បត្តិរបស់ **អ្នកធានា** ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ មិនមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត ។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទចាប់ផ្តើមការសាងសង់ (Construction Commencement Date) រហូតដល់បញ្ចប់អាណត្តិ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង ឬកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី និងបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល **អ.ក** ជំពាក់ **ក្រុមហ៊ុន** ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់ ។ ប៉ុន្តែទោះបីយ៉ាងណា ចំពោះការធានាលើ ថ្លៃកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ក្នុងករណីដែល **អ.ក** ពុំបានទូទាត់ថ្លៃប្រើប្រាស់សមត្ថភាពគម្រោង លិខិតធានានេះ ត្រូវមានប្រសិទ្ធភាព ចាប់ពីថ្ងៃដំណើរការអាជីវកម្មនៃគម្រោង (Commercial Operation Date) ដូចមាននិយមន័យកំណត់នៅក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយ ដោយ **ក្រុមហ៊ុន** ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយក្រោមការធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬមួយផ្នែក ដោយភាគីណាមួយ ច្រានចោលការអនុវត្តបន្ថែមផ្សេងទៀត ឬការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយផ្សេងទៀត ។ ការបដិសេធរបស់ **ក្រុមហ៊ុន** មានប្រសិទ្ធភាព លុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យ **ក្រុមហ៊ុន** ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់ឡើយ ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលបន្ទាប់ពីនេះទៅ ត្រូវហៅរួមគ្នាថា **«លិខិតជូនដំណឹង»**) ដែលត្រូវផ្តល់ ឬធ្វើឡើង ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាស័យដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថាបានប្រគល់:

(ក) ពេលប្រគល់ផ្ទាល់ដៃ ឬ

(ខ) នៅពេលប្រគល់មានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារអន្តរជាតិ ដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅអាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិត តាមអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម):

សម្រាប់ **អ្នកធានា**:

| | |
|---|---|
| ជូនចំពោះ | : **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** |
| អាស័យដ្ឋាន | : ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារលេខ | : ៨៥៥-២៣ ៤២៧ ៧៩៨ |

សម្រាប់ **ក្រុមហ៊ុន**:

| | |
|---|---|
| អាស័យដ្ឋាន | : រោងចក្រអគ្គិសនីទី២, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែលើ, ខណ្ឌមានជ័យ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា |
| ជូនចំពោះ | : **លោកនាយកប្រតិបត្តិ** |
| ទូរសារលេខ | : ៨៥៥ ២៣ ៤២៥ ៩៩០ |

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. **អ្នកធានា** មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពី **ក្រុមហ៊ុន** ឡើយ ហើយ **ក្រុមហ៊ុន** មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងនេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពី **អ្នកធានា** ឡើយ។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍របស់គម្រោង **ក្រុមហ៊ុន** អាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់អ្នកឱ្យខ្ចីប្រាក់។

លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានអត្ថប្រយោជន៍ដល់ **អ្នកធានា** និង **ក្រុមហ៊ុន** ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់ **អ្នកធានា** និង **ក្រុមហ៊ុន** ក្រោម ឬអនុលោមតាមលិខិតធានានេះ ត្រូវបានគ្រប់គ្រង និងបកស្រាយតាមច្បាប់អង់គ្លេស ដែលនឹងត្រូវជាច្បាប់គ្រប់គ្រងនីតិវិធីមជ្ឈត្តវិនិច្ឆ័យផងដែរ។

ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធទៅនឹងលិខិតធានានេះ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ **អ្នកធានា** និង **ក្រុមហ៊ុន** ត្រូវសាកល្បងដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សាជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបានតាមរយៈការពិភាក្សាជាមិត្តភាពទេ គេត្រូវដាក់វិវាទនោះទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអចេ្ន វវាងមាត្រានេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ មាត្រានេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើ **អ្នកធានា** និង **ក្រុមហ៊ុន** និងអាចយកមកអនុវត្តនៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការធ្វើឱ្យសេចក្តីសម្រេចនេះ អនុវត្តបាន។ ភាគីទាំងនោះ ត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយដែលគេអាចមាន ដើម្បីតវ៉ាអំពីសុពលភាព នៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះមានប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេច របស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេច ពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១១. ពាក្យសរសេរជាអក្សរធំដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី តាមដែលអាចអនុវត្តបាន។

ប្រសិនបើបញ្ញត្តិណាមួយឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថាគ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិនោះពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិសេសសល់ផ្សេងទៀត នៃលិខិតធានានេះឡើយ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារ ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែល **អ្នកធានា** មាន ឬអាចមានចំពោះ **ក្រុមហ៊ុន** ត្រូវតែមានសម្រាប់ **អ្នកធានា** ចំពោះ **ក្រុមហ៊ុន** ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់ **អ្នកធានា** ចំពោះ **ក្រុមហ៊ុន** ស្របតាមលិខិតធានានេះ។

១២. លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនី ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានានេះដដែល ហេតុដូចនេះ ការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយ ពី **ក្រុមហ៊ុន** ជូនមក **អ្នកធានា** ត្រូវតែទទួលបានមុនពេលផុតកំណត់នោះ។

១៣. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តទៅបាន បន្ទាប់ពីទទួលបានការអនុម័ត ពីស្ថាប័ននីតិបញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការស្រឡាញ់រាប់អាន ដ៏ជ្រាលជ្រៅ អំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**ជំនួសមុខ និង ក្នុងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា**

**គាត ឈន់**

**ចម្លងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ